**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# អនុស្សរណៈនៃការយោគយល់
# រវាង
# សហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វ៊លហ្គ្រេនឌីអង្គរ
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វ៊លហ្គ្រេនឌីអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី៦ ខែមេសា ឆ្នាំ២០២០ រវាងសហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វ៊លហ្គ្រេនឌីអង្គរ (ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វ៊លហ្គ្រេន ឌីអង្គរ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Grand Hotel d'Angkor កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃជំងឺកូរ៉ូណាវីរុស ទូទាំងពិភពលោកបានបណ្តាលឱ្យមានការបញ្ឈប់ការធ្វើដំណើរអន្តរជាតិទាំងអស់ ហេតុដូចនេះហើយ សណ្ឋាគារត្រូវបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន ដោយចាប់ផ្តើមពី ថ្ងៃពុធ ទី០៨ ខែមេសា ឆ្នាំ២០២០ តទៅ។ ដូច្នេះ និយោជក និងសហជីពបានចរចាគ្នាអំពីគម្រោងផ្តល់ប្រាក់ឈ្នួលការងារក្នុងអំឡុងពេលនៃការព្យួរដើម្បីជួយសម្រាលបន្ទុកសម្រាប់ទាំងសណ្ឋាគារ និងនិយោជិតក្នុងកំឡុងពេលព្យួរនេះ រហូតដល់អាជីវកម្មវិលត្រឡប់មករកកម្រិតដែលប្រសើរ។

គូភាគីទាំងពីរព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

និយោជិតនឹងត្រូវព្យួរការងារជាបណ្តោះអាសន្នចាប់ពីថ្ងៃទី ០៨ ខែមេសាឆ្នាំ ២០២០តទៅ។

- និយោជិតនឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ឈ្នួលគោលប្រចាំខែ ក្នុងអំឡុងពេលនៃការព្យួរការងារ។
- និយោជិតនឹងទទួលបាន**អង្ករ ១០ គីឡូក្រាម** [ស្មើ ៧.៥ ដុល្លារអាមេរិក] ជារៀងរាល់ខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ នឹងបន្តក្នុងកំឡុងការព្យួរការងារ។
- អតីតភាពការងារនឹងមិនទទួលរងផលប៉ះពាល់។
- និយោជិតនឹងយកការឈប់សម្រាកប្រចាំឆ្នាំ និងថ្ងៃឈប់សំរាកបុណ្យជាតិដែលនៅសល់ រួមទាំងថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ២០២០ មុនពេលចាប់ផ្តើមអនុវត្តន៍គម្រោងព្យួរការងារ។

សណ្ឋាគារនឹងតម្រូវឱ្យនិយោជិតមួយចំនួនបន្តធ្វើការពេញម៉ោងក្នុងអំឡុងពេលនៃការផ្អាកប្រតិបត្តិការនេះ ដើម្បីថែទាំសណ្ឋាគារ។

- និយោជិតទាំងនេះនឹងទទួលបានប្រាក់ឈ្នួល ១០០%។
- និយោជិតដែលបំពេញការងារក្នុងអំឡុងពេលផ្អាកប្រតិបត្តិការសណ្ឋាគារនឹងទទួលបានប្រាក់ឧបត្ថម្ភធ្វើដំណើរបន្ថែមចំនួន **៣០ ដុល្លារ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រនឹងនៅតែមានជាធម្មតា។
- និយោជិតដែលបំពេញភារកិច្ចនឹងទទួលបានអាហារជាធម្មតា។
- និយោជិតទាំងនេះអាចនឹងត្រូវបានស្នើសុំឱ្យបំពេញការងារក្រៅកាតព្វកិច្ចធម្មតារបស់ខ្លួន។ ប៉ុន្តែ ការបណ្តុះបណ្តាលដែលសមរម្យនឹងត្រូវបានផ្តល់ដើម្បីធានាថាកិច្ចការអាចត្រូវបានបញ្ចប់ដោយសុវត្ថិភាព (ឧទាហរណ៍៖ បុគ្គលិកផ្នែក

ម្ហូបអាហារនិងភេសជ្ជៈធ្វើការសំអាតអាងទឹក)។ ក្នុងករណីមានការកក់សណ្ឋាគារជាក្រុមភ្លាមៗក្នុងកំឡុងពេលផ្អាកប្រតិបត្តិការ និយោជិតមួយចំនួនឬទាំងអស់ អាចត្រូវបានគេតម្រូវឱ្យមកធ្វើការ។ និយោជិតនឹងទទួលបាន ប្រាក់ឈ្នួល ១០០% នៃប្រាក់ឈ្នួលប្រចាំថ្ងៃធម្មតារបស់ពួកគេ (ដោយមិនមានប្រាក់ឧបត្ថម្ភសំរាប់ការធ្វើដំណើរ, ខណៈប្រាក់ធានានុគ្រោះត្រូវបានផ្តល់ជូនសំរាប់និយោជិកដែលបានបំពេញភារកិច្ច)។

នៅពេលស្ថានភាពជំងឺ Covid-19 មានភាពប្រសើរឡើងវិញ និយោជកនឹងមានកាតព្វកិច្ចទាក់ទងនិយោជិតគ្រប់ៗគ្នាដើម្បីវិលត្រឡប់មកធ្វើការងារដូចធម្មតាវិញ ហើយអត្ថប្រយោជន៍ដែលមាននៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួមនឹងត្រូវរក្សានៅដដែល។

សូមបញ្ជាក់ថាកិច្ចព្រមព្រៀងនេះនឹងចាប់ផ្តើមអនុវត្តន៍នៅថ្ងៃ ទី៨ ខែមេសា ឆ្នាំ២០២០ រហូតដល់មានការជូនដំណឹងបន្ថែម។ ជាមួយនឹងស្ថានភាពពិភពលោកផ្លាស់ប្តូរយ៉ាងឆាប់រហ័ស កិច្ចព្រមព្រៀងនេះនឹងចាំបាច់ត្រូវពិនិត្យឡើងវិញលើមូលដ្ឋានប្រចាំខែ។

គូភាគីព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់នេះដោយចុះហត្ថលេខាខាងក្រោមនេះ៖

| ចុះហត្ថលេខាតាងនាមភាគីនិយោជក | ចុះហត្ថលេខាតាងនាមភាគីសហជីព |
|---|---|
| Oliver Dudler<br>នាយកសណ្ឋាគារ | រស់ ប៊ុនណាល់<br>ប្រធានសហជីព |
| Vincent Gernigon<br>អ្នកគ្រប់គ្រងសណ្ឋាគារ | 07-Apr-20<br>ជើង គីវុធ<br>អនុប្រធានសហជីព |
| 7/4/20<br>អ៊ុង ចន្ទ្រា<br>នាយកធនធានមនុស្ស | 07-Apr-20<br>ម៉ៅ វណ្ណដា<br>លេខាធិការសហជីព |
| 07/4/20<br>សាន់ ណារដ្ឋ<br>ប្រធានហិរញ្ញវត្ថុ | ប៉ាត សំបូរ<br>ប្រធានកិត្តិយសសហជីព |